ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខៈ ០៦ ប្រ.ក ប.ស្ថ / ១៩២៣

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌ និងនីតិវិធីនៃការទទួលស្គាល់ ក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៧ និងតារាងឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ និងឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- យោងប្រកាសលេខ ២១០ ប្រក.បស្ថ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំបច្ចេកទេសស្តីពីការបំពាក់បរិក្ខារ និងកិច្ចដំណើរការប្រព្រឹត្តិកម្មសំណល់រាវ
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន



អគារមរតកតេជោ ដីឡូត៍លេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.–**

ប្រកាសនេះ កំណត់អំពីលក្ខខណ្ឌ នីតិវិធី និងលក្ខណៈវិនិច្ឆ័យ សម្រាប់ការផ្តល់ ការព្យួរ និងការលុបចោលលិខិតទទួលស្គាល់ការផ្តល់សេវាវិស្វកម្មបរិស្ថានរបស់ក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវនៅតាមទីតាំងផលិតកម្ម អាជីវកម្ម និងសេវាកម្ម ដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹក ធានាបាននូវសុវត្ថិភាពសុខភាពសាធារណៈ និងការអភិរក្សជីវៈចម្រុះ។

**ប្រការ២.–**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះគ្រប់ក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ នៅតាមបណ្តាទីតាំងផលិតកម្ម អាជីវកម្ម និងសេវាកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.–**

បច្ចេកសព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ** សំដៅដល់ក្រុមហ៊ុនដែលផ្តល់សេវាវិស្វកម្មបរិស្ថាន លើការរចនាប្លង់ស្ថាបត្យកម្ម ការសាងសង់ ការបំពាក់បរិក្ខារ ដំណើរការប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ និងបំពាក់បរិក្ខារប្រព័ន្ធស្វ័យត្រួតពិនិត្យ
- **សំណល់រាវ** សំដៅដល់វត្ថុរាវ ដែលបញ្ចេញពីទីតាំងផលិតកម្ម អាជីវកម្ម និងសេវាកម្ម ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬ ចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តិកម្ម ឬ មិនបានធ្វើប្រព្រឹត្តិកម្មក្តី
- **ប្រព្រឹត្តិកម្មសំណល់រាវ** សំដៅដល់សកម្មភាព ឬ លំនាំសម្អាត ដកយកចេញ ឬ កាត់បន្ថយ ឬ បំប្លែងនូវសារធាតុបំពុលទឹកមានក្នុងទឹកសំណល់ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងមហន្តរាយដល់បរិស្ថានទឹក ដី ខ្យល់ និងជីវៈចម្រុះ
- **លិខិតទទួលស្គាល់ការផ្តល់សេវាវិស្វកម្មបរិស្ថាន** សំដៅលើលិខិតអនុញ្ញាតដែលចេញដោយក្រសួងបរិស្ថាន ដល់ក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ សម្រាប់ប្រតិបត្តិការផ្តល់សេវាវិស្វកម្មបរិស្ថាន លើការរចនាប្លង់ស្ថាបត្យកម្ម ការសាងសង់ ការបំពាក់បរិក្ខារ ដំណើរការប្រព្រឹត្តិកម្មសំណល់រាវ និងបំពាក់បរិក្ខារប្រព័ន្ធស្វ័យត្រួតពិនិត្យ។

## ជំពូកទី២

## លិខិតទទួលស្គាល់ការផ្តល់សេវាវិស្វកម្មបរិស្ថាន

**ប្រការ៤.–**

ក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ដែលស្ថិតក្រោមវិសាលភាពនៃប្រកាសនេះ ត្រូវមានកាតព្វកិច្ចបំពេញបែបបទ ដើម្បីទទួលបានការទទួលស្គាល់ការផ្តល់សេវាវិស្វកម្មបរិស្ថានពីក្រសួងបរិស្ថាន។

ការទទួលស្គាល់ការផ្តល់សេវាវិស្វកម្មបរិស្ថាន ត្រូវបានផ្តល់ជូនក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ បន្ទាប់ពីក្រសួងបរិស្ថានបានពិនិត្យឃើញថា បានបំពេញបែបបទស្នើសុំត្រឹមត្រូវ និងលទ្ធផលនៃការចុះត្រួតពិនិត្យវាយតម្លៃនៅទីតាំងផ្ទាល់ បានឆ្លើយតបតាមការតម្រូវ។

## ជំពូកទី៣
## លក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យក្នុងការទទួលបាន
## លិខិតទទួលស្គាល់ការផ្តល់សេវាវិស្វកម្មបរិស្ថាន

### ប្រការ៥._

ក្រុមហ៊ុនដែលមានបំណងស្នើសុំលិខិតទទួលស្គាល់ការផ្តល់សេវាវិស្វកម្មបរិស្ថាន ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១- មានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។

២- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណពន្ធប៉ាតង់។

៣- មានរចនាសម្ព័ន្ធគ្រប់គ្រង និងបុគ្គលិកជំនាញវិជ្ជាជីវៈវិស្វកម្មបរិស្ថានពាក់ព័ន្ធនឹងប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ។

៤- ភ្ជាប់ជាមួយនូវសាវតាររបស់ក្រុមហ៊ុនលើការរចនាប្លង់ស្ថាបត្យកម្ម ការសាងសង់ ការបំពាក់បរិក្ខារ និងកិច្ចដំណើរការប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ និងការបំពាក់ឧបករណ៍វិភាគគុណភាពទឹកស្វ័យប្រវត្តិ និងកិច្ចដំណើរការប្រព័ន្ធវិភាគគុណភាពទឹកស្វ័យប្រវត្តិតាមការវិវត្តកម្មបច្ចេកវិទ្យា និងបច្ចេកទេស។

៥- ផែនការបណ្តុះបណ្តាលដល់បុគ្គលិកម្ចាស់គម្រោងដែលទទួលសេវា អំពីការប្រតិបត្តិអាងប្រព្រឹត្តិកម្មសំណល់រាវ។

៦- ត្រូវមានកិច្ចសន្យាការពារបរិស្ថាន និងបង់មូលនិធិបរិស្ថាននិងសង្គម។

### ប្រការ៦._

ក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងនាយកក្រុមហ៊ុន អ្នកគ្រប់គ្រងទូទៅ ប្រធានក្រុមបច្ចេកទេស និងអ្នកជំនាញបច្ចេកទេស។

ករណីមានការផ្លាស់ប្តូរសមាសភាពទាំងនេះ ក្រុមហ៊ុនត្រូវជូនដំណឹងជាមុនមកក្រសួងបរិស្ថាន មិនឱ្យលើសពីរយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ។

### ប្រការ៧._

នាយកក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- មានបទពិសោធន៍ក្នុងការគ្រប់គ្រង និងមានការយល់ដឹងលើការងារបរិស្ថាន
- ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល ឬ សិក្ខាសាលាពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន
- ធ្លាប់មានបទពិសោធន៍ក្នុងការគ្រប់គ្រង និងដំណើរការប្រព័ន្ធវិភាគគុណភាពទឹកស្វ័យប្រវត្តិ។

**ប្រការ៨.-**

អ្នកគ្រប់គ្រងទូទៅក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅពាក់ព័ន្ធនឹងជំនាញគ្រប់គ្រង ស្ថាបត្យកម្ម វិស្វកម្មសំណង់ស៊ីវិល វិទ្យាសាស្ត្របរិស្ថាន ឬ សញ្ញាបត្រសមមូល
- មានបទពិសោធន៍ក្នុងការគ្រប់គ្រង និងមានការយល់ដឹងលើការងារបរិស្ថាន
- ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល ឬ សិក្ខាសាលាពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន
- ធ្លាប់មានបទពិសោធន៍ក្នុងការគ្រប់គ្រង និងដំណើរការប្រព័ន្ធវិភាគគុណភាពទឹកស្វ័យប្រវត្តិ។

**ប្រការ៩.-**

ប្រធានក្រុមបច្ចេកទេសក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅលើជំនាញ ស្ថាបត្យកម្ម វិស្វកម្មសំណង់ស៊ីវិល វិទ្យាសាស្ត្របរិស្ថាន ឬ សញ្ញាបត្រសមមូល
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការរចនាប្លង់ស្ថាបត្យកម្ម សាងសង់ បំពាក់បរិក្ខារ ដំណើរការប្រព្រឹត្តិកម្មសំណល់រាវ និងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច ៥(ប្រាំ)ឆ្នាំ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការបំពាក់ឧបករណ៍វិភាគគុណភាពទឹកស្វ័យប្រវត្តិ និងដំណើរ-ការប្រព័ន្ធវិភាគគុណភាពទឹកស្វ័យប្រវត្តិយ៉ាងតិច ៣(បី)ឆ្នាំ។

**ប្រការ១០.-**

អ្នកជំនាញបច្ចេកទេសក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅលើជំនាញ ស្ថាបត្យកម្ម វិស្វកម្មសំណង់ស៊ីវិល វិទ្យាសាស្ត្របរិស្ថាន និងវិទ្យាសាស្ត្រជំនាញពាក់ព័ន្ធ ឬ សញ្ញាបត្រសមមូល
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការរចនាប្លង់ស្ថាបត្យកម្ម សាងសង់ បំពាក់បរិក្ខារ ប្រព្រឹត្តិកម្មសំណល់រាវ និងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច ៣(បី)ឆ្នាំ
- មានវិញ្ញាបនបត្របណ្តុះបណ្តាលពាក់ព័ន្ធនឹងការរចនាប្លង់ស្ថាបត្យកម្ម សាងសង់ បំពាក់បរិក្ខារ ដំណើរការប្រព្រឹត្តិកម្មសំណល់រាវ បំពាក់ឧបករណ៍វិភាគគុណភាពទឹកស្វ័យប្រវត្តិ និងដំណើរ-ការប្រព័ន្ធវិភាគគុណភាពទឹកស្វ័យប្រវត្តិ។

## ជំពូកទី៤
## ការបង់កម្រៃសេវា

**ប្រការ១១.-**

ក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ត្រូវបង់ថ្លៃសេវាស្នើសុំលិខិតទទួលស្គាល់ការផ្តល់សេវាវិស្វកម្មបរិស្ថាន និងសេវាផ្សេងទៀត ដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## ជំពូកទី៥
## សុពលភាព ការព្យួរ ការលុបចោល
## លិខិតទទួលស្គាល់ការផ្ដល់សេវាវិស្វកម្មបរិស្ថាន

**ប្រការ១២.–**

លិខិតទទួលស្គាល់ការផ្ដល់សេវាវិស្វកម្មបរិស្ថាន របស់ក្រុមហ៊ុនផ្ដល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ មានសុពលភាពរយៈពេល ៥(ប្រាំ)ឆ្នាំ។

**ប្រការ១៣.–**

ក្រុមហ៊ុនផ្ដល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ដែលមានបំណងបន្តសុពលភាពលិខិតទទួលស្គាល់ការផ្ដល់សេវាវិស្វកម្មបរិស្ថាន ត្រូវដាក់ពាក្យស្នើសុំមកក្រសួងបរិស្ថាន យ៉ាងតិច ៤៥ (សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃផុតសុពលភាព។

**ប្រការ១៤.–**

ត្រូវបានព្យួរចាប់ពីរយៈពេល៦(ប្រាំមួយ)ខែ ដល់២(ពីរ)ឆ្នាំ ក្នុងសុពលភាព ចំពោះលិខិតទទួលស្គាល់ការផ្ដល់សេវាវិស្វកម្មបរិស្ថាន របស់ក្រុមហ៊ុនផ្ដល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ក្នុងករណីដូចខាងក្រោម៖

- មានកំហុសបច្ចេកទេស ឬ ធ្វេសប្រហែសក្នុងការរៀបចំគម្រោងសាងសង់អាងប្រព្រឹត្តិកម្មសំណល់រាវ មិនអនុលោមតាមគោលការណ៍ណែនាំបច្ចេកទេស
- មិនបានអនុវត្តតាមកាតព្វកិច្ច ដែលមានចែងក្នុងលិខិតទទួលស្គាល់ការផ្ដល់សេវាវិស្វកម្មបរិស្ថាន
- ខកខានមិនបានជូនដំណឹងមកក្រសួងបរិស្ថានដូចមានចែងក្នុងប្រការ៦ នៃប្រកាសនេះ។

**ប្រការ១៥.–**

ត្រូវបានលុបចោល លិខិតទទួលស្គាល់ការផ្ដល់សេវាវិស្វកម្មបរិស្ថាន របស់ក្រុមហ៊ុនផ្ដល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ក្នុងករណីដូចខាងក្រោម៖

- នៅតែបំពានលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៤ នៃប្រកាសនេះ
- អាងប្រព្រឹត្តិកម្មសំណល់រាវ ពុំមានសមត្ថភាពធ្វើប្រព្រឹត្តិកម្មបានឆ្លើយតបទៅនឹងស្តង់ដារបញ្ចេញ និងបង្កឱ្យមានការបំពុលបរិស្ថានធ្ងន់ធ្ងរ
- ត្រូវបានផ្តន្ទាទោសពីបទព្រហ្មទណ្ឌណាមួយ។

**ប្រការ១៦.–**

ក្រុមហ៊ុនផ្ដល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ពុំអាចដាក់ពាក្យស្នើសុំលិខិតទទួលស្គាល់ការផ្ដល់សេវាវិស្វកម្មបរិស្ថានឡើងវិញបានទេ ក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំ បន្ទាប់ពីលិខិតទទួលស្គាល់ការផ្ដល់សេវាវិស្វកម្មបរិស្ថាននោះ ត្រូវបានលុបចោល។

# ជំពូកទី៦
# អន្តរប្បញ្ញត្តិ

**ប្រការ១៧.–**

ក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ដែលទទួលបានលិខិតទទួលស្គាល់សមត្ថភាពលើការងារវិស្វកម្មបរិស្ថានមុនប្រកាសនេះចូលជាធរមាន ត្រូវដាក់ពាក្យស្នើសុំលិខិតទទួលស្គាល់ការផ្តល់សេវាវិស្វកម្មបរិស្ថានមកក្រសួងបរិស្ថានជាថ្មីឡើងវិញ ស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះ។

ក្នុងករណីលិខិតទទួលស្គាល់ការផ្តល់សេវាវិស្វកម្មបរិស្ថាននេះ ពុំត្រូវបានផ្តល់ជូនឡើងវិញដូចមានចែងក្នុងកថាខណ្ឌខាងលើ ក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ត្រូវបញ្ចប់ការងារដែលនៅសេសសល់ឱ្យរួចរាល់ក្នុងរយៈពេល ១(មួយ)ឆ្នាំ ជាកំហិត។

# ជំពូកទី៧
# អវសានប្បញ្ញត្តិ

**ប្រការ១៨.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៩.–**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ គ្រប់ក្រុមហ៊ុនផ្តល់សេវាវិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ និងម្ចាស់/ឬ អ្នកទទួលខុសត្រូវលើ ទីតាំងផលិតកម្ម អាជីវកម្ម និងសេវាកម្មទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕ ៣

ថ្ងៃ ព្រហស្បតិ៍ ១៥កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**អ៊ាង សុផល្លែត**

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ